# អំពី ការពិនិត្យរកមើល ជំងឺមហារីកសួត



វិធីដ៏ល្អបំផុតដើម្បីស្វែងរកមើលជំងឺមហារីកសួតនៅដំណាក់កាលដំបូង គឺការពិនិត្យរកមើលជំងែមហារីកសួតឱ្យបានទៀងទាត់។

ជំងឺមហារីកសួតគឺជាមូលហេតុចម្បងនៃការស្លាប់ដោយសារជំងឺមហារីកនៅក្នុងប្រទេសអូស្ត្រាលី។ ប៉ុន្តែប្រសិនបើរកឃើញនៅដំណាក់កាលដំបូង ករណីភាគច្រើនអាចព្យាបាលបានដោយជោគជ័យ។

ការជក់បារីគឺជាកត្តាហានិភ័យធំបំផុតសម្រាប់ជំងឺមហារីកសួត។

ជំងឺមហារីកសួតគឺជាជំងឺមហារីកមួយក្នុងចំណោមជំងឺមហារីកទូទៅបំផុតនៅទូទាំងពិភពលោក។

ជំងឺមហារីកសួតចាប់ផ្តើមនៅពេលដែលកោសិកានានាលូតលាស់ដែលមិនអាចគ្រប់គ្រងបាននៅក្នុងសួត។

ការពិនិត្យមើលតាមរយៈរបកគំហើញជំងឺមហារីកនៅដំណាក់កាលដំបូងមុនពេលមានរោគសញ្ញានានានៅពេលដែលវាមិនពិបាកក្នុងការព្យាបាល ឬមើលឱ្យជាសះស្បើយ។

Australian Government

NATIONAL LUNG CANCER SCREENING PROGRAM

## តើការពិនិត្យរកមើលជំងឺមហារីកសួតជាអ្វី?

ការពិនិត្យរកមើលជំងឺមហារីកសួត ពាក់ព័ន្ធនឹងការស្កេនដោយកុំព្យូទ័រថតរូបភាពកាំរស្មីអ៊ិចដូសកម្រិតទាប (CT) ដើម្បីរកមើលសញ្ញានានានៃជំងឺមហារីកសួតនៅដំណាក់កាលដំបូង។ ការពិនិត្យគឺសម្រាប់អ្នកដែលមិនមានរោគសញ្ញានានា (ឧទាហរណ៍ ក្អកដែលមិនជាសះស្បើយ ក្អកមានឈាម)។

ការពិនិត្យរកមើលជំងឺមហារីកសួតប្រើការស្កេន CT ដូសកម្រិតទាប (វិទ្យុសកម្មដូសកម្រិតទាប) ដើម្បីរកមើលដុំណាមួយដែលហៅថា ដុំពកតូចៗ។ ដុំតូចៗភាគច្រើននឹងមិនមែនជាជំងឺមហារីកទេ។

ការស្កេន CT ដូសកម្រិតទាបសម្រាប់ការពិនិត្យរកមើលជំងឺមហារីកសួតគឺឥតគិតថ្លៃ ដែលគ្របដណ្តប់ដោយ Medicare។

## ហេតុអ្វីបានជាវាសំខាន់?

ជំងឺមហារីកសួតគឺជាមូលហេតុចម្បងនៃការស្លាប់ដោយសារជំងឺមហារីកនៅក្នុងប្រទេសអូស្ត្រាលី។ ប៉ុន្តែប្រសិនបើរកឃើញនៅដំណាក់កាលដំបូង ករណីភាគច្រើនអាចព្យាបាលបានដោយជោគជ័យ។

ការពិនិត្យគឺសម្រាប់មនុស្សដែលមានសុខភាពល្អ ដែលមិនមានរោគណាមួយ។ ការពិនិត្យអាចជួយសង្គ្រោះជីវិតអ្នក។

នៅពេលដែលមហារីកសួតចាប់ផ្តើមដំបូង វាមិនមានរោគសញ្ញាអ្វីឡើយ។ រោគសញ្ញានានាដូចជា ក្អកមានឈាម ឬការស្រកទម្ងន់ដែលមិនអាចពន្យល់បាន អាចមានន័យថា ជំងឺមហារីកសួតកាន់តែរីកចម្រើនទៅមុខហើយ។

ពេលវេលាដ៏ល្អបំផុតដើម្បីព្យាបាលជំងឺមហារីកសួត គឺនៅពេលដែលដុំពកតូចៗត្រូវបានរកឃើញនៅដំណាក់កាលដំបូង។ នៅពេលដែលជំងឺមហារីកសួតត្រូវបានរកឃើញនៅដំណាក់កាលដំបូង វាមិនពិបាកព្យាបាលទេ ហើយមនុស្សភាគច្រើនបានធូរស្បើយ និងត្រឡប់ទៅជីវិតធម្មតាវិញ។

វាជារឿងសំខាន់ក្នុងការពិនិត្យ ទោះបីជាអ្នកមានអារម្មណ៍ល្អក៏ដោយ។



## តើខ្ញុំមានសិទ្ធិទទួលទេ?

អ្នកមានសិទ្ធិទទួលបានកម្មវិធីនេះ ប្រសិនបើអ្នកបំពេញតាមលក្ខណៈវិនិច្ឆ័យទាំងអស់ខាងក្រោម៖

**មានអាយុពី 50 ទៅ 70 ឆ្នាំ**

**និង**

**មិនមានរោគសញ្ញា ឬសញ្ញានានាដែលបង្ហាញថាកើតជំងឺមហារីកសួត**
(ឧទាហរណ៍ ក្អកជាប់រហូតមិនអាចពន្យល់បាន ក្អកមានឈាម ដង្ហើមខ្លីដោយគ្មានមូលហេតុ)

**និង**

**ជក់បារី ឬមានប្រវត្តិជក់បារី**
(ឈប់ជក់ក្នុងរយៈពេល 10 ឆ្នាំ)

**និង**

**មានប្រវត្តិជក់បារីយ៉ាងហោចណាស់ 30 ឆ្នាំកញ្ចប់**
(ឧទាហរណ៍ មួយកញ្ចប់ក្នុងមួយថ្ងៃអស់រយៈពេល 30 ឆ្នាំ ឬ 2 កញ្ចប់ក្នុងមួយថ្ងៃអស់រយៈពេល 15 ឆ្នាំ)

**សូមពិភាក្សាជាមួយវេជ្ជបណ្ឌិតរបស់អ្នក ដើម្បីមើលថាតើអ្នកមានសិទ្ធិទទួលដែរឬទេ។**



## តើខ្ញុំគួរទៅនៅពេលណា?

ពិភាក្សាជាមួយវេជ្ជបណ្ឌិតរបស់អ្នកដើម្បីមើលថាតើអ្នកមានសិទ្ធិសម្រាប់កម្មវិធីដែរឬទេ។ ប្រសិនបើអ្នកមានសិទ្ធិទទួល អ្នកអាចធ្វើការស្កេនរៀងរាល់ពីរឆ្នាំម្តង។ អ្នកនឹងត្រូវទៅជួបគ្រូពេទ្យដើម្បីបញ្ជូនអ្នកទៅស្កេន។ អ្នកគួរតែធ្វើការពិនិត្យ ទោះបីជាអ្នកមានអារម្មណ៍ល្អក៏ដោយ។

## ចុះបើខ្ញុំមានរោគសញ្ញានានា?

ប្រសិនបើអ្នកមានរោគសញ្ញាទាំងនេះ ទោះបីជាការធ្វើតេស្តពិនិត្យចុងក្រោយរបស់អ្នកមានហានិភ័យទាបបំផុត ឬអ្នកស្ថិតនៅចន្លោះការស្កេន សូមពិគ្រោះជាមួយវេជ្ជបណ្ឌិតរបស់អ្នកភ្លាមៗ។

- **ការក្អកថ្មី ឬការក្អកបានផ្លាស់ប្តូរ**
- **ការក្អកមានឈាម**
- **ការដកដង្ហើមខ្លីដោយគ្មានហេតុផល**
- **អស់កម្លាំងយ៉ាងខ្លាំង**
- **ការសម្រកទម្ងន់ដែលមិនអាចពន្យល់បាន។**
- **ឈឺទ្រូងឬស្មាដែលមិនបាត់**

**សម្រាប់ព័ត៌មានបន្ថែមអំពីកម្មវិធីពិនិត្យ រកមើលជំងឺមហារីកសួតថ្នាក់ជាតិ៖**

www.health.gov.au/nlcsp

Quitline 13 7848

**សម្រាប់ជំនួយក្នុងការផ្តាច់បារី៖**

www.quit.org.au

DT0004838_V01